# មូលនិធិ GALING POOK

GALING POOK ចាប់ផ្តើមនៅនៅឆ្នាំ១៩៩៣ គឺខណៈពេលដែលមានការរៀបចំកម្មវិធីផ្តល់រង្វាន់ជាលើកទីមួយ។ កម្មវិធីផ្តល់រង្វាន់ស្នាដៃត្រូវបានផ្តួចផ្តើមរួមគ្នារវាងបុគ្គលដែលទាមទារចង់មានអភិបាលកិច្ចល្អពីមជ្ឈដ្ឋានសិក្សា សង្គមស៊ីវិល និងពីរដ្ឋាភិបាល។ មូលនិធិ Galing Pook ត្រូវបានបង្កើតជាផ្លូវការឱ្យក្លាយជានីតិបុគ្គលផ្តល់រង្វាន់ស្នាដៃឯកជន នៅឆ្នាំ១៩៩៨ ដើម្បីធានាចីរភាពកម្មវិធីផ្តល់រង្វាន់ស្នាដៃ។

ក្រោយការបង្កើតបានជិតពីរទសវត្សរ៍ Gale Pook ក្លាយជាស្ថាប័នធនធាននាំមុខដែល លើកស្ទួយការបង្កើតថ្មី និងស្នាដៃចំនាន ជាបន្តបន្ទាប់ នៅថ្នាក់អភិបាលមូលដ្ឋាន។ មូលនិធិធ្វើការស្រាវជ្រាវនាំមុខដើម្បីជំរុញបំផុស និងទទួលស្គាល់ការអនុវត្តល្អដាច់គេរបស់រដ្ឋាភិបាលមូលដ្ឋាន ហើយសម្របសម្រួលការអនុវត្តឱ្យសាយភាយបានដល់សហគមន៍ច្រើនទៀត ពាសពេញប្រទេស។

## រង្វាន់ស្នាដៃដែលផ្តល់ដោយមូលនិធិ Galing Pook

រង្វាន់ស្នាដៃដែលផ្តល់ដោយមូលនិធិ **Galing Pook** ចាប់ផ្តើមមាននៅថ្ងៃទី ២១ តុលា ១៩៩៣ ជាកម្មវិធីមិនធ្លាប់មានដែលស្រាវជ្រាវ និងទទួលស្គាល់សកម្មភាពបង្កើតថ្មី របស់អង្គភាពអភិបាលមូលដ្ឋាន (LGU)។ អ្នកជាប់ចំណាត់ថ្នាក់របស់អង្គភាពអភិបាលមូលដ្ឋាន (LGU) ដែលមានគំនិតផ្តួចផ្តើមលេចធ្លោ ត្រូវបានជ្រើសរើសដោយម៉ត់ចត់ ហើយអ្នកឈ្នះ ត្រូវបានទទួលស្គាល់ស្នាដៃក្នុងពិធីផ្តល់រង្វាន់ប្រកបដោយកិត្យានុភាពខ្ពស់។ ពានរង្វាន់ត្រូវបានប្រគល់ជូនដោយប្រធានាធិបតីសាធារណៈរដ្ឋហ្វីលីពីន។

អ្នកទទួលពានរង្វាន់របស់មូលនិធិ Galing Pook គឺជ្រើសរើសដោយផ្អែកស្រាវជ្រាវជាតិ នៃកម្មវិធីអភិបាលមូលដ្ឋានផង ហើយវាយតំលៃដោយឆ្លងកាត់ដំណើរការជំរុះតឹងតែងជាច្រើនជាន់ថ្នាក់ផ្អែកលើលទ្ធផលនិងឥទ្ធិពលជាវិជ្ជមាន ផ្អែកលើគោលការណ៍លើកកំពស់ការចូលរួមរបស់ប្រជាជន និងការផ្តល់អំណាច ផ្អែកលើការដែលអាចផ្ទេរបន្ត ឬធ្វើសារថ្មី និងចីរភាព ព្រមទាំងផ្អែកលើ ប្រសិទ្ធិផលនៃការផ្តល់សេវារបស់កម្មវិធី។

ក្រៅពីការផ្តល់រង្វាន់ កម្មវិធីដែលឈ្នះត្រូវក្លាយជាកម្មវិធីគំរូរបស់អភិបាលកិច្ចល្អដែលត្រូវតែងតាំងដោយមានការយល់ព្រមទទួលស្គាល់ពីសហគមន៍ដ៏ទៃផ្សេងទៀតផងដែរ។ គំរោងទាំងនោះផ្តល់ជាយុទ្ធសាស្ត្រនិងភាពច្បាស់លាស់ ដ៏មានសារប្រយោជន៍ ដើម្បីស្វែងរកដំណោះស្រាយតាមរបៀបថ្មីចំពោះបញ្ហាទាំងឡាយ។ ជាសារប្រយោជន៍ កម្មវិធីទាំងនោះផ្តល់ឱ្យសហគមន៍និងគណកម្មការអភិបាលកិច្ចល្អទទួលបានអភិបាលកិច្ចល្អ។

ចាប់តាំងពីមូលនិធិចាប់ផ្តើម យ៉ាងហោចណាស់កម្មចំនួន ២១៥ របស់រដ្ឋាភិបាលមូលដ្ឋានចំនួន ១៣៦ បានទទួល រង្វាន់ពី Galing Pook ។ អ្នកទទួលរង្វាន់ទាំងនោះបានក្លាយជាមានសារសំខាន់បំផុតដែលជួយគាំទ្រ

នៅក្នុងការ  លើកជាកម្លាំង  និងបំផុសជាគំនិតដល់រដ្ឋាភិបាលមូលដ្ឋានដើម្បបង្ហាញពីការអនុវត្តតាមរបៀបថ្មី  និង ផ្តល់ជាបរិយា កាសល្អសំរាប់ការឆ្លើយតបការកំណែទម្រង់ដោយជោគជ័យ ។

**ប្រភេទរង្វាន់:**

- កម្មវិធីអភិបាលកិច្ចល្អនៅមូលដ្ឋានដែលធ្វើការប្រសើរបំផុតចំនួន១០
- រង្វាន់សំរាប់ឧត្តភាពដែលកំពុងបន្តរ
- ការលើកសសើរជាពិសេស

**លក្ខខំណ្ឌនៃការផ្តល់រង្វាន់:**

| | |
|---|---|
| • សម្រេចលទ្ធផលវិជ្ជមាន | ៣៥% |
| • ការលើកកម្ពស់នៃការចូលរួមរបស់ប្រជាពលរដ្ឋនិងការផ្តល់អំណាយឱ្យប្រជាពលរដ្ឋ | ៣៥% |
| • មានតម្លាភាពនិងស្ថិរភាព | ២០% |
| • ប្រសិទ្ធភាពនៃការបែងចែកសេវាកម្មវិធី | ១០% |

http://www.galingpook.org